■改編自：新北市教育局
陪你快樂學柬埔寨語
□自編

111 年新北市各級學校東南亞語文競賽
團體朗讀文稿柬埔寨 國小組 B-1

# ម្ហូបអាហារពិសេស

ម៉ាក់: ទើបលចុះពីយន្តហោះ តើកូនទាំងអស់គ្នាចង់ទៅញ៉ាំអាហារថ្ងៃត្រង់នៅហាងម្ហូបអាហារខ្មែរដែររឺទេ?

សុខា: តើម្ហូបអាហារមានភាពខុសគ្នាអ្វីខ្លះដែលអាចញ៉ាំបាន?

ម៉ាក់: មាននំបញ្ចុកសម្លខ្មែរ បាយសាច់ជ្រូកចៀន គុយទាវភ្នំពេញ ហើយមានម្ហូបអាហារដែលខុសពីតៃវ៉ាន់ជាច្រើន កូនទាំងអស់គ្នាអាចញ៉ាំសាកល្បងមើលបាន។

បងស្រី: តើជូរខ្លាំងដែររឺទេ?

ប្អូនស្រី: តើហិលដែររឺទេ?

ម៉ាក់: មានជូរតិចៗ ប៉ុន្តែមិនជូរពេកទេ។

ម៉ាក់: មានម្ហូបអាហារខ្លះហិលតិចៗ ក៏មានអាហារអត់ហិលដែរ សុទ្ធតែអាចញ៉ាំបានទាំងអស់។

សុខា: តើមានភេសជ្ជៈដែររឺទេ?

ម៉ាក់: មាន ប៉ុន្តែទាល់ញ៉ាំអាហាររួចទើបអាចផឹកបាន។

(ពោល) : ញ៉ាំអាហារថ្ងៃត្រង់រួច មួយគ្រួសារនាំគ្នាទៅដើរលេងផ្សារធំថ្មីទាំងអស់គ្នា។

ប្អូនស្រី: ខ្ញុំមិនដែលឃើញទេ តើនោះជាអ្វី?

ម៉ាក់: នោះជាផ្លែឈ្យូក មានគ្រាប់ឈ្យូកនៅខាងក្នុងអាចញ៉ាំ
ឆៅបាន នៅតែវ៉ាន់ មានឃើញតែគ្រាប់ឈ្យូកនិងមឹម
ឈ្យូកនៅក្នុងផ្សារ។

បងស្រី: ម៉ាក់ តើនេះផ្លែឈើអ្វី?

ម៉ាក់: នោះគឺជាផ្លែសៅមៅ បន្តិចទៀតម៉ាក់ត្រូវទិញផ្លែទឹក
ដោះគោនិងចេកពងមាន់ថែមទៀតយកទៅផ្ទះយាយ។

សុខា: ចេកនឹងតូចមែនទែន!

(ពោល) : ម៉ាក់និយាយសើច

ម៉ាក់: ហាសហា! នោះជាចេកពងមាន់ មិនមែនជាចេកធម្មតាទេ។

បងស្រី ប្អូនស្រី: ហាសហា ហាសហា ហាសហា

(ពោល) : មួយគ្រួសារទាំងអស់គ្នាយួរផ្លែឈើជិះរថយន្ត
ធ្វើដំណើរទៅផ្ទះយាយ។